លេខសំគាល់ ៖ ____________________
កាលបរិច្ឆេទប្រជុំ ៖ថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០១៩

# កិច្ចសន្យា A ៖ សារាចរអំពីគោលនយោបាយនៃកិច្ចព្រមព្រៀងផលលាភរបស់សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស*

## ផ្នែកទី១៖ គោលបំណង

គោលបំណងនៃសារាចរនេះ គឺចង់បង្ហាញពីការអនុវត្តកម្មវិធីសមភាពរបស់សហគមន៍ជ្រលងភ្នំ*ឌូវ៉ាមីស្ស* (Duwamish Valley Community Equity Program) និង ប្រតិបត្តិការរបស់កំពង់ផែដទៃទៀត ដែលជះឥទ្ធិពលដល់សហគមន៍ជ្រលងភ្នំ*ឌូវ៉ាមីស្ស*។ ការអនុវត្តសារាចរនេះ អាចឲ្យកំពង់ផែ*ស៊ីអាថល* ពង្រីកបេសកម្មរបស់ខ្លួន ក្នុងការលើកកម្ពស់ឱកាសសេដ្ឋកិច្ច និងគុណភាពជីវិតនៅក្នុងតំបន់ តាមរយៈការជំរុញឲ្យមានការធ្វើពាណិជ្ជកម្ម ទេសចរណ៍ ការធ្វើអាជីកម្ម និង ការបង្កើតការងារ ប្រកបដោយសមភាព គណនេយ្យភាព និងការទទួលខុសត្រូវចំពោះបរិស្ថាន។ ដៃគូរបស់កំពង់ផែជាមួយនឹងក្រុមប្រឹក្សាសហគមន៍ និងក្រុមការងារសកម្មរបស់សហគមន៍កំពង់ផែ (Port Community Action Team) នឹងធានាថាកម្មវិធី DVCEP សម្រេចបានគោលដៅរួមចំនួនបី ៖

ក. គោលដៅទី១ ៖ ការកសាងសមត្ថភាពរបស់សហគមន៍ និងកំពង់ផែ សម្រាប់កិច្ចសហការបច្ចុប្បន្ននិងអនាគត
ខ. គោលដៅទី២ ៖ បរិស្ថានស្អាត និងសហគមន៍ប្រកបដោយសុខភាពល្អ
គ. គោលដៅទី៣ ៖ ភាពសម្បូរធូធារនៃសេដ្ឋកិច្ចនៅក្នុងតំបន់

## ផ្នែកទី២៖ និយមន័យ

នៅក្នុងកិច្ចព្រមព្រៀងនេះ គេនឹងពន្យល់អត្ថន័យនៃពាក្យ និងឃ្លាមួយចំនួន ដូចមានបង្ហាញនៅខាងក្រោមនេះ លើកលែងតែបរិបទណាដែលគេបង្ហាញន័យផ្សេងពីនេះយ៉ាងច្បាស់លាស់។

"Allyship" (សាមគ្គីភាព) គឺជាការអនុវត្តយ៉ាងសកម្ម ស៊ីសង្វាក់គ្នា និង ខិតខំការកែប្រែដោយអស់លទ្ធភាព និងវាយតម្លៃឡើងវិញ ដែលក្នុងនោះបុគ្គល ឬស្ថាប័នាណាមួយដែលមានអំណាចជាប្រព័ន្ធ ព្យាយាមបញ្ឈប់ការគាបសង្កត់ដោយរួបរួមគ្នាជាមួយមនុស្សមួយក្រុមដែលមិនមានអំណាច។

"Anti-Displacement" (ការប្រឆាំងនឹងការផ្លាស់ប្តូរទីលំនៅ) គឺជាគោលនយោបាយ យុទ្ធសាស្ត្រ និងការអនុវត្តទាំងឡាយណា ដែលរារាំងពីការផ្លាស់ប្តូរទីលំនៅណាមួយ តាមរយៈការកសាងសមត្ថភាពសហគមន៍ ដើម្បី

គ្រប់គ្រងការផ្លាស់ប្តូរសហគមន៍ ដោយបង្កើនការទទួលបានការងារធ្វើ អាជីព និងគាំទ្រអោយមានកន្លែងដែលសមាជិកសហគមន៍អាចជួបជុំគ្នា ដើម្បីពង្រឹងវប្បធម៌របស់ខ្លួន (ដូចមានបង្ហាញនៅក្នុងផ្នែកទី២៖ និយមន័យ) ។

"Climate Resilience" (ភាពធន់នឹងការប្រែប្រួលអាកាសធាតុ) គឺចង់សំដៅលើការស្តារ និងការរីកលូតលាស់ឡើងវិញរបស់សហគមន៍ និងបរិស្ថានក្នុងតំបន់ បន្ទាប់ពីមានព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរណាមួយ ព្រមទាំងការតស៊ូនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុរយៈពេលវែង។ នេះរួមបញ្ចូលទាំងការដោះស្រាយរកឫសគល់នៃបញ្ហាអាកាសធាតុ និងការអភិវឌ្ឍប្រព័ន្ធសេដ្ឋកិច្ចសង្គម ដែលអាចកាត់បន្ថយភាពតានតឹង និងរក្សាដំណើរការក្នុងខណៈដែលកំពុងមានបញ្ហា ដើម្បីអោយសហគមន៍ដែលប៉ះពាល់អាចរីកចម្រើនដោយមិនបាច់ប្តូរទីតាំង ។

"Community Capacity Building" (ការកសាងសមត្ថភាពសហគមន៍) គឺជាដំណើរការដែលសមាជិក និងក្រុមការងារសហគមន៍ទទួលបាន កែលម្អ និង រក្សានូវជំនាញ ចំណេះដឹង ឧបករណ៍ សម្ភារៈ និងធនធានចាំបាច់ផ្សេងៗទៀត ដើម្បីចូលរួមរៀបចំគម្រោងប្រកបដោយប្រសិទ្ធភាព និងដំណើរការរៀបចំផែនការ និងការសម្រេចចិត្ត ព្រមទាំងការតាំងចិត្តដោយខ្លួនឯង ចំពោះការសម្រេចចិត្តលើគោលនយោបាយ និងគម្រោងផ្សេងៗ។

"Community Engagement" (ការចូលរួមរបស់សហគមន៍) គឺជាដំណើរការរួមគ្នា ដែលជាដំណើរការប្រជាធិបតេយ្យ ដែលតាមរយៈដំណើរការនេះ គេផ្តល់អំណាចឲ្យសមាជិកសហគមន៍ និងបុគ្គលិករបស់កំពង់ផែ ធ្វើការរួមគ្នាក្នុងការសម្រេចចិត្ត។ ការចូលរួមនេះ រួមមានការកែលម្អទំនាក់ទំនងសហគមន៍ជាមួយកំពង់ផែ ការពង្រឹងអំណាចសហគមន៍ ការកសាងសមត្ថភាព និងភាពជាដៃគូ ការប្រើប្រាស់ធនធានប្រកបដោយសមភាព ការគោរព និងការយល់ដឹងពីវប្បធម៌ ព្រមទាំងការទទួលស្គាល់តម្លៃនៃទស្សនៈវិស័យ និងបទពិសោធន៍ផ្សេងៗ។

"Community Science" (វិទ្យាសាស្រ្តសហគមន៍) គឺជាទម្រង់នៃការស្រាវជ្រាវដែលមានការចូលរួមរបស់សហគមន៍ ដែលជួយឲ្យអ្នកចូលរួមចេះស្វែងយល់ វិភាគ ចែករំលែកព័ត៌មាន និង ចាត់វិធានការលើបញ្ហាដែលប៉ះពាល់ដល់សហគមន៍។

"Cultural Competence" (ការយល់ដឹងពីវប្បធម៌) គឺជាជំនាញ អាកប្បកិរិយា និងគោលការណ៍ណែនាំអំពីការចូលរួមប្រកបដោយភាពជោគជ័យ និងប្រសិទ្ធភាព ជាមួយនឹងមនុស្សដែលតំណាងឲ្យវប្បធម៌ផ្សេងៗ ស្ថានភាពសេដ្ឋកិច្ចសង្គម និងបទពិសោធន៍រស់នៅ។

"Disaggregated data" (ទិន្នន័យបែបវិភាគ) គឺជាទិន្នន័យទាំងឡាយណាដែលគេបែងចែកជាចំណាត់ថ្នាក់យ៉ាងលម្អិត ដូចជាពូជសាសន៍ ភេទ ឬក៏ការធ្វើជំរឿន។ ទិន្នន័យបែបវិភាគ អាចបង្ហាញពីភាពមិនសមមាត្រ ដែលគេមិនអាចបង្ហាញច្បាស់លាស់នៅក្នុងទិន្នន័យ។

“Displacement” (ការផ្លាស់ប្តូរទីលំនៅ) គឺជាការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន ឬក៏អាជីវកម្មទាំងឡាយណាដោយពុំមានការព្រៀងទុកជាមុន ពីទីតាំងបច្ចុប្បន្នរបស់ពួកគេ។ នេះគឺជាស្ថានភាពដោយឡែក នៅពេលដែលម្ចាស់អចលនទ្រព្យណាមួយ លក់ភាគហ៊ុនរបស់ពួកគេដោយស្ម័គ្រចិត្ត ដើម្បីបង្កើនប្រាក់ចំណេញ។ Physical (direct) displacement (ការផ្លាស់ប្តូរទីលំនៅដោយមានការបង្ខិតបង្ខំ) គឺជាការបណ្តេញចេញ ការដាក់ទោសទណ្ឌ ការសាងសង់ឡើងវិញ និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ដែលបណ្តាលមកពីការផុតកំណត់កិច្ចព្រមព្រៀងលើការជួលលំនៅដ្ឋាន ឬការរស់នៅផ្ទះសម្រាប់អ្នកដែលមានប្រាក់ចំណូលទាប។ Economic (indirect) displacement (ការផ្លាស់ប្តូរទីតាំងដោយសារបញ្ហាហិរញ្ញវត្ថុ) គឺកើតឡើងនៅពេលដែល ប្រជាជន ឬអាជីវកម្មណាមួយ ពុំមានលទ្ធភាពបង់ឈ្នួលផ្ទះ ឬពន្ធលំនៅដ្ឋានដែលចេះតែកើនឡើង។ Cultural displacement (ការផ្លាស់ប្តូរទីតាំងដោយសារបញ្ហាវប្បធម៌) គឺកើតឡើងនៅពេលដែលប្រជាជនជ្រើសរើសការផ្លាស់ប្តូរលំនៅដ្ឋានពីព្រោះអ្នកភូមិ និងមុខរបររកស៊ីដែលទាក់ទងនិងវប្បធម៌របស់ពួកគេ លែងមាននៅតំបន់នោះទៀតហើយ។

Duwamish Valley Community (សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស*) គឺជាក្រុមមនុស្ស និងក្រុមសហគមន៍ដែលពួកគេរស់នៅ ធ្វើការ លេងកំសាន្ត សិក្សារៀនសូត្រ ឬប្រារព្ធពិធីសាសនាផ្សេងៗ នៅជិតតំបន់នានាក្បែរកំពង់ផែនៃតំបន់ *សៅផាក* (South Park) និង *ចចថោន* (Georgetown) តាមបណ្តោយដងទន្លេ *ឌូវ៉ាមីស្ស*។ សហគមន៍ទាំងនេះ រួមមានអ្នកស្រុក *ឌូវ៉ាមីស្ស* និងអ្នកស្រុកដើមរបស់ទីក្រុង *ស៊ីអាថល* ធ្លាប់ទទួលរង និងកំពុងទទួលរងនូវផលប៉ះពាល់ពីភាពលំអៀងនៃសេដ្ឋកិច្ច ការប្រកាន់ពូជសាសន៍ និងភាពលំអៀងនៅក្នុង សង្គម។ ការកែប្រែនិយមន័យនេះត្រូវតែមានការយល់ព្រមពីបណ្តាដៃគូនៃសហគមន៍។

“Duwamish Valley Community Equity Program” (DVCEP) (កម្មវិធីប្រកបដោយសមភាពរបស់ សហគមន៍ជ្រលង*វ៉ាមីស្ស*) គឺជាកម្មវិធីរបស់កំពង់ផែ*ស៊ីអាថល* ដែលធានាថាការសន្យាផ្តល់ផលលាភដល់ សហគមន៍នេះ នឹងត្រូវអនុវត្តតាមរយៈការវិនិយោគដែលមានផែនការកំណត់ជាក់លាក់ និងកិច្ចសហការជាមួយនឹងសហគមន៍នេះ។ កម្មវិធីនេះ រួមមានសកម្មភាពដែលកំពង់ផែ នឹងអនុវត្តន៍ដើម្បីទទួលបានជោគជ័យ ក្នុងកិច្ចព្រមព្រៀងគ្នារវាងកំពង់ផែ និងសហគមន៍ លើគោលដៅក្នុងការកំណត់ផលលាភ។

“Equitable engagement” (ការចូលរួមប្រកបដោយសមភាព) គឺជាដំណើរការចូលរួមរបស់សហគមន៍ ដើម្បីធានាឲ្យបានថា ភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់ច្រើនជាងគេ (ឧ. ប្រជាជនភាគតិច និងគ្រួសារដែលមានប្រាក់ចំណូលទាប) អាចចូលរួមនៅក្នុងដំណើរការនៃការសម្រេចចិត្ត។ ការចូលរួមប្រភេទនេះ គឺត្រូវសកម្ម ចេះយោគយល់គ្នា ឆ្លើយតប រួបរួមគ្នា និងយល់ពីវប្បធម៌របស់គ្នាទៅវិញទៅមក។

“Equity” (សមភាព) គឺជាការផ្តល់ការយកចិត្តទុកដាក់ ការទទួលបានព័ត៌មាន ការផ្តល់ឱកាស និងភាពរីកចម្រើន ប្រកបដោយស្មើភាពគ្នាសម្រាប់មនុស្សគ្រប់រូប ហើយទន្ទឹមនឹងក៏រកនូវបញ្ហា និង លុបបំបាត់ឧបសគ្គទាំងឡាយណា ដែលរារាំងដល់ការចូលរួមពេញលេញរបស់ក្រុមមនុស្សមួយចំនួន។ ការកែលម្អសមភាព មានដូចជា៖ ១. ធ្វើឲ្យនិតិវិធី និងដំណើរការអនុវត្តនៃស្ថាប័នានាប្រកបដោយយុត្តិធម៌ និងសមភាព ២. ធ្វើការបែងចែកធនធានប្រកបដោយសមភាព។ ឧទាហរណ៍ គេយល់ថាសមភាពនៃពូជសាសន៍ណាមួយ គឺជាឬសគល់នៃភាពមិនស្មើគ្នា ហើយរឿងនេះបណ្តាលអោយ មានការលុបបំបាត់ការរើសអើងជាតិសាសន៍ចេញពីក្នុងគោលនយោបាយទាំងអស់ ក្នុងការអនុវត្ត ក្នុងអាកប្បកិរិយា និងការប្រើប្រាស់សារទាក់ទងនឹងវប្បធម៌ នៅក្នុងកម្រិតសង្គម ស្ថាប័ន និងនិតិបុគ្គល។

“Environmental justice” (ភាពយុត្តិធម៌ក្នុងសង្គម) គឺជាពាក្យមួយសម្រាប់ឆ្លុះបញ្ចាំងពីតថភាពនៃសហគមន៍ទាំងឡាយណាដែលធ្លាប់ និងកំពុងរងគ្រោះ ហើយជួបប្រទះនូវបញ្ហាជាច្រើនដូចជា ការបំពុលបរិស្ថាន ភាពអយុត្តិធម៌ និងបញ្ហាផ្សេងៗ។ ភាពយុត្តិធម៌នៅក្នុងសង្គម រួមបញ្ចូលគោលការណ៍ដែលប្រជាជន និងសហគមន៍ទាំងអស់ មានសិទ្ធិក្នុងការទទួលបានបរិស្ថានប្រកបដោយសុខភាពល្អ និងទទួលការការពារ និងការអនុវត្តច្បាប់ និងបទបញ្ញត្តបរិស្ថានប្រកបដោយសមភាព។

“Green economy” (សេដ្ឋកិច្ចបៃតង) គឺជាសេដ្ឋកិច្ចទាំងឡាយណាដែលផ្តោតលើការកាត់បន្ថយហានិភ័យ ផ្នែកបរិស្ថាន និងកង្វះខាតប្រភពធនធាន ព្រមទាំងជួយលើកកម្ពស់ដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយមិនធ្វើឲ្យប៉ះពាល់បរិស្ថាន ដែលនាំឲ្យប្រជាជនទទួលបានសុខភាពល្អ និងភាពស្មើគ្នា។

“Greenspace” (តំបន់បៃតង) គឺជាបរិវេណនៃកំពង់ផែដែលផ្តល់ជាទីកន្លែងដល់សាធារណៈជនមកកំសាន្ត និងស្រូបយកខ្យល់អាកាសខាងក្រៅ យ៉ាងហោចណាស់ផ្នែកខ្លះនៃបរិវេណត្រូវគ្របដណ្តប់ដោយរុក្ខជាតិ។

“Institutional racism” (ការរើសអើងជាតិសាសន៍កម្រិតស្ថាប័ន) គឺជាមធ្យោបាយនៃការអនុវត្តគោលនយោបាយ និងនិតិវិធីនៃស្ថាប័នមួយ ដែលផ្តល់សមិទ្ធផលផ្សេងគ្នាសម្រាប់ជាតិសាសន៍ផ្សេងៗ ពោលគឺផលប្រយោជន៍ដែលប្រជាជនស្បែកស និងផលអវិជ្ជមានដែលប្រជាជនភាគតិចទទួលបាន។ ឧទាហរណ៍ គេអាចឃើញមានភាពមិនស្មើគ្នាបានដូចជា តាមរយៈការខ្វះខាតនៃការទទួលបានការងារធ្វើ ដែលជាផលដោយផ្ទាល់មកពីការរើសអើងជាតិសាសន៍ ឬផលដោយប្រយោលតាមរយៈភាពអសមត្ថភាពរបស់បុគ្គលណាមួយដែលមិនមានឥទ្ធិពល ទៅលើការសម្រេចចិត្តរបស់រដ្ឋាភិបាល ដោយសារតែការខ្វះខាតអ្នកតំណាងរបស់ពួកគេនៅក្នុងនោះ។

"LGBTQAI" (មនុស្សភេទទី៣) គឺជាអក្សរកាត់នៃពាក្យ Lesbian (មនុស្សស្រីស្រឡាញ់ភេទដូចគ្នា) Gay (មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា) Bisexual (មនុស្សប្រុសឬស្រីស្រឡាញ់ភេទទាំងពីរ) Transgender (មនុស្សប្រុសឬស្រីប្តូរភេទ) queer (មនុស្សប្រុសឬស្រីដែលមានអាកប្បកិរិយាផ្ទុយពីភេទរបស់ខ្លួនប៉ុន្តែពួកគេស្រឡាញ់ភេទផ្ទុយគ្នា) asexual (មនុស្សប្រុសឬស្រីឬភេទទី៣ដែលគ្មានចំណង់ផ្លូវភេទ) Intersex (មនុស្សប្រុសឬស្រីដែលមានរាងកាយផ្ទុយពីភេទរបស់ពួកគេប៉ុន្តែពួកគេស្រឡាញ់ភេទផ្ទុយគ្នា)។ ជាទូទៅ គេច្រើនតែមើលរំលងពីអត្តសញ្ញាណនៃភេទ និងជេនឌឺខាងលើនេះ។

"Northwest Ports Clean Air Inventory and Strategy" (ការចុះបញ្ជី និងយុទ្ធសាស្ត្របរិយាកាសបរិសុទ្ធនៃកំពង់ផែភាគពាយ័ព្យ) គឺជាកិច្ចខំប្រឹងប្រែងរួមគ្នារវាងកំពង់ផែ *ស៊ីអាថល* និងកំពង់ផែ *តាកូម៉ា* រួមទាំងសម្ព័ន្ធកំពង់ផែសមុទ្រភាគពាយ័ព្យ (NWSA) និងអាជ្ញាធរកំពង់ផែ *វេនឃូវើហ្វ្រេស័រ* នៃប្រទេសកាណាដា ដើម្បីកាត់បន្ថយការ បំភាយឧស្ម័នពុលពីប្រតិបត្តិការដឹកជញ្ជូនតាមកប៉ាល់ និងកំពង់ផែ នៅស្ថានីយចម្រោះខ្យល់នៃតំបន់ *ចចជៀ បេស៊ីន ផូហ្គេតសោន* (Georgia Basin Puget Sound)។

"The Northwest Seaport Alliance" (សម្ព័ន្ធកំពង់ផែសមុទ្រភាគពាយ័ព្យ) គឺជាដៃគូប្រតិបត្តិការដឹកទំនិញតាមផ្លូវសមុទ្រនៃកំពង់ផែ *តាកូម៉ា* និងកំពង់ផែ *ស៊ីអាថល* ដែលកំពង់ផែទាំងពីរនេះ ជាច្រកទ្វារចេញចូលផ្ទុកឡាំងទំនិញកុងតេន័រធំជាងគេទី៤នៅសហរដ្ឋអាមេរិក។

"Port Capacity Building" (ការកសាងសមត្ថភាពរបស់កំពង់ផែ) គឺជាដំណើរការដែលអ្នកដឹកនាំ បុគ្គលិក និងអ្នកតំណាងផ្សេងៗរបស់កំពង់ផែ ទទួលបានការបណ្តុះបណ្តាល ចំណេះដឹង ជំនាញ និងឧបករណ៍ប្រើប្រាស់ផ្សេងៗ រួមមានសាមគ្គីភាព និងចំណេះដឹងពីសង្គម។ ទាំងនេះ រួមមានការបង្កើតសាជីវកម្មផ្សេងៗប្រកបដោយសមភាព និងមានគោលការណ៍រួមគ្នា ក្នុងការសម្រេចចិត្ត និងការចូលរួមរបស់សហគមន៍។

"Port Community Action Team" (ក្រុមការងារសកម្មនៃកំពង់ផែរបស់សហគមន៍) គឺជាក្រុមអ្នកផ្តល់ប្រឹក្សារបស់សហគមន៍ បង្កើតឡើងនៅឆ្នាំ២០១៧។ ក្រុមនេះ កើតចេញពីសមាជិកសហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* ដែលចូលរួមក្នុងកិច្ចសហការ និងការរៀបចំផែនការយុទ្ធសាស្ត្រជាមួយកំពង់ផែផ្សេងៗ ដើម្បីដោះស្រាយបញ្ហា ដែលមានតាំងពីអតីតកាល និងបច្ចុប្បន្នកាល ដែលជះឥទ្ធិពលដល់សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស*។

"Priority Hire Policy" (គោលនយោបាយជួលបុគ្គលិកអាទិភាព) បង្កើតឡើង យោងតាមសេចក្តីសម្រេចលេខ ៣៧៣៦ របស់កំពង់ផែ *ស៊ីអេថល* ដែលធ្វើវិសោធនកម្មដោយសេចក្តីសម្រេចលេខ៣៧៤៦ និងអនុម័ត្រដោយគណៈកម្មាការកំពង់ផែ *ស៊ីអាថល* ដើម្បីបង្កើនការទទួលបានការងារសម្រាប់កម្មករសំណង់ដែលមានគុណសម្បត្តិ

គ្រប់គ្រាន់តាមតម្រូវការ។ កម្មករទាំងនោះ ភាគច្រើនមកពីតំបន់ដែលមានវិបត្តិសេដ្ឋកិច្ចនៃ *យីងខោនធី* និងមកពីគម្រោងសាងសង់ផ្សេងៗរបស់កំពង់ផែ *ស៊ីអាថល* ។

"Welcoming Port Policy" (គោលនយោបាយបដិសណ្ឋារកិច្ចរបស់កំពង់ផែ) បង្កើតឡើងក្នុងគោលបំណងដើម្បីបង្កើនការចូលរួម និងការគាំទ្រដល់សហគមន៍នៃជនអន្តោប្រវេសន៍ និងជនភាសខ្លួន យោងតាមសេចក្តីសម្រេចលេខ៣៧៤៧ របស់កំពង់ផែ *ស៊ីអេថល*។

## ផ្នែកទី៣៖ វិសាលភាព និងការអនុវត្ត

កិច្ចព្រមព្រៀងនេះ សំដៅលើសកម្មភាពរបស់បុគ្គលិកនៃកំពង់ផែ *ស៊ីអាថល* និងអង្គភាពអាជីវកម្មពាក់ព័ន្ធទាំងឡាយណា ដែលប៉ះពាល់ដល់សហគមន៍។ សកម្មភាពខាងលើនេះ អាចប្រព្រឹត្តទៅបានក្រោមការអនុញ្ញាតរបស់អាជ្ញាធរកំពង់ផែ និងគោលនយោបាយរបស់កំពង់ផែ។ បុគ្គលិករបស់កំពង់ផែ មានសិទ្ធិក្នុងការសម្រេចថាតើក្រុមហ៊ុនម៉ៅការ និងម្ចាស់អាជីវកម្មទាំងអស់របស់កំពង់ផែត្រូវអនុវត្តកិច្ចព្រមព្រៀងនេះយ៉ាងដូចម្តេច។ បុគ្គលិកក្រុមហ៊ុនម៉ៅការ និងម្ចាស់អាជីកម្ម ព្រមទាំងអង្គភាពអាជីវកម្មទាំងអស់របស់កំពង់ផែ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងដំណើរការអាជីវកម្មរបស់កំពង់ផែ ដូចមានចែងនៅក្នុងខ្លឹមសារនៃកិច្ចសន្យានេះ។

ដើម្បីធានាអោយមានសមភាព និងសកម្មភាពផ្សេងៗដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ យើងត្រូវព្យាយាមដោះស្រាយបញ្ហាទាំងឡាយណាដែលមានភាពលំអៀង និងមានផលប៉ះពាល់ដល់សមាជិកសហគមន៍ សហគមន៍នៃប្រជាជនភាគតិច ជនជាតិដើមអាមេរិក កម្មករដែលមានប្រាក់ចំណូលទាប អ្នកស្រុក ជនភាសខ្លួន ជនអន្តោប្រវេសន៍ និតិបុគ្គលដែលរស់នៅខុសច្បាប់ អតីតយុទ្ធជន យុវជន និងមនុស្សចាស់ និតិបុគ្គលដែលធ្លាប់មាន ប្រវិត្តជាទណ្ឌិត មនុស្សភេទទី៣ ជនពិការ ក្រុមមនុស្សណាមួយដែលចំណេះដឹងភាសាអង់គ្លេសរបស់ពួកគេមានកម្រិត សហគ្រាសអាជីកម្មដែលមានស្ត្រីឬជនជាតិភាគតិចជាម្ចាស់អាជីវកម្ម (WMBE) ព្រមទាំងអង្គការដែលដឹកនាំដោយប្រជាជនភាគតិចឬស្ត្រី។

## ផ្នែកទី៤៖ ភារកិច្ច

ក. នាយកប្រតិបត្តិ ឬប្រតិភូ ត្រូវមានកាតព្វកិច្ច ទទួលបន្ទុកក្នុងការធានាឲ្យការអនុវត្តន៍ និងមានថវិកាប្រចាំឆ្នាំគ្រប់គ្រាន់សំរាប់កម្មវិធីសមភាពនៃសហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* (DVCEP)។

ខ. នាយកប្រតិបត្តិ ឬប្រតិភូ ត្រូវរៀបចំផែនការយុទ្ធសាស្ត្ររៀងរាល់បីឆ្នាំម្តង រួមមានយុទ្ធសាស្ត្រ និងសកម្មភាពផ្សេងៗ ដើម្បីជានាឲ្យកម្មវិធីនេះទទួលបានភាពជោគជ័យ។ ផែនការយុទ្ធសាស្ត្រនេះ រួមបញ្ចូលជាមួយនឹងផែនការការប្រចាំឆ្នាំ។ ផែនការការប្រចាំឆ្នាំ បង្កើតឡើងដោយមានការចូលរួមពីក្រុមអ្នកផ្តល់ប្រឹក្សារបស់ក្រុមការងារសកម្មរបស់កំពង់ផែសហគមន៍ (PCAT)។ បុគ្គលិករបស់កំពង់ផែ ត្រូវធ្វើការជាមួយនឹងសហគមន៍ ដើម្បីជានាឲ្យការអនុវត្តកម្មវិធីអាទិភាព សកម្មភាពផ្សេងៗ វិធានការគ្រប់គ្រង និងប្រព័ន្ធវាស់វែង ប្រកបដោយភាពជោគជ័យ។

គ. នាយកប្រតិបត្តិ ឬប្រតិភូ ត្រូវជានាឲ្យមានការចូលរួមពីគ្រប់អង្គភាពរបស់កំពង់ផែ នៅក្នុងក្រុមការងារអន្តរអង្គភាពជ្រលងភ្នំ*ឌូវ៉ាមីស្ស* រួមមាន៖ ទំនាក់ទំនងខាងក្រៅ បរិស្ថាន និងនិរន្តរភាព ដែនសមុទ្រ ធនធានមនុស្ស ការអភិវឌ្ឍន៍សេដ្ឋកិច្ច ការិយាល័យសមភាព ភាពចម្រុះ និងការរួមបញ្ចូលគ្នា (office of equity, diversity and inclusion) សម្ព័ន្ធកំពង់ផែសមុទ្រភាគពាយព្យ (NWSA) អ្នកតំណាងគណៈកម្មាការ ក្រុមការងារ ចាំបាច់មួយចំនួនទៀត ដើម្បីសម្រេចគោលដៅ ដោយមានការពិគ្រោះយោបល់ជាមួយនឹងអង្គភាពនិតិកម្ម។

## ផ្នែកទី៥៖ គោលនយោបាយ

ក. **សេចក្តីផ្តើម៖** គោលនយោបាយផលលាភរបស់សហគមន៍ជ្រលងភ្នំ*ឌូវ៉ាមីស្ស* ផ្តល់ការណែនាំអំពីទំនាក់ទំនងបច្ចុប្បន្ន និងនាពេលអនាគត រវាងកំពង់ផែ*ស៊ីអាថល* និងសហគមន៍ជ្រលងភ្នំ*ឌូវ៉ាមីស្ស*។ គោលនយោបាយនេះ ត្រូវអនុវត្តតាមរយៈការវិនិយោគរយៈពេលវែងនិងការជ្រើសរើសក្រុមការងាររបស់កម្មវិធីសមភាពនៃសហគមន៍ជ្រលងភ្នំ*វ៉ាមីស្ស* (DVCEP)។ កម្មវិធីនេះ ត្រូវសម្រេចគោលដៅចំនួន៣ខាងក្រោមនេះ៖

### ខ. គោលដៅទី១៖ ការកសាងសមត្ថភាពរបស់កំពង់ផែ និងសហគមន៍ សម្រាប់កិច្ចសហការបន្ត

គោលដៅនេះ អនុវត្តស្របនឹងគំនិតផ្តួចផ្តើមប្រកបដោយសមភាពរបស់កំពង់ផែ ដើម្បីដោះស្រាយបញ្ហារើសអើងជាតិសាសន៍នៅក្នុងសង្គម និង ទទួលស្គាល់ថាវិធីសាស្ត្រដ៏ប្រសិទ្ធភាពបំផុត សម្រាប់ដោះស្រាយភាពមិនស្មើគ្នាដែលកើតឡើងនៅក្នុងសហគមន៍ផ្ទាល់។ កម្មវិធី DVCEP ត្រូវកសាងសមត្ថភាពរបស់កំពង់ផែ និងសហគមន៍ ដើម្បីជានាឲ្យការចូលរួម និងភាពជាដៃគូ ប្រកបដោយសមភាព និងនិរន្តភាព។ ដើម្បីសម្រេចគោលដៅនេះ កម្មវិធី DVCEP ត្រូវជំរុញឲ្យមានការសម្រេចចិត្តរួមគ្នា ការគាំទ្រមេដឹកនាំសហគមន៍បច្ចុប្បន្ន និងអនាគត និងការចូលរួមជាមួយសហគមន៍ លើសកម្មភាពមួយចំនួនដែលផ្តល់ជាសមិទ្ធផលផ្លែផ្កាដល់ភាគីពាក់ព័ន្ធទាំងអស់។ សកម្មភាពទាំងនោះរួមមាន៖

១. <u>ការបញ្ចូលគ្នា</u>

បង្កើនការទទួលព័ត៌មាន និងការផ្សព្វផ្សាយកម្មវិធី សកម្មភាពផ្សេងៗ និងការប្រើប្រាស់សេវាសាធារណៈរបស់កំពង់ផែ ប្រកបដោយសមភាព។ ជូនដំណឹងដល់សហគមន៍អំពីបច្ចុប្បន្នភាព និងព័ត៌មានផ្សេងៗរបស់កំពង់ផែ។ កែសម្រួលយុទ្ធសាស្ត្រផ្សព្វផ្សាយរបស់កំពង់ផែ ដូចជាការរៀបចំកម្មវិធី ឬ ផ្សាយ

ព័ត៌មានផ្សេងៗ។ ផ្សព្វផ្សាយនៅតាមបណ្តាញសារព័ត៌មានរបស់សហគមន៍ជនជាតិភាគតិច ដោយផ្តល់សេវាបកប្រែសម្រាប់កម្មវិធីរបស់កំពង់ផែ និងបង្កើនការផ្សព្វផ្សាយព័ត៌មានអំពីផលប៉ះពាល់ និងឱកាសផ្សេងៗ តាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដូចជា វិទ្យុ វិដេអូ និងវេទិកាតាមប្រព័ន្ធអ៊ីនធើណេត ដើម្បីឲ្យដឹងដល់ទស្សនិកជនថ្មីទៀត។ ផ្សព្វផ្សាយព័ត៌មានដល់សហគមន៍អំពីគោលនយោបាយបដិសណ្ឋារកិច្ចរបស់កំពង់ផែ ការជួញដូរមនុស្ស និងកម្មវិធីផ្សេងៗរបស់កំពង់ផែ ដែលមានប្រយោជន៍ដល់ជនភាសខ្លួន និងជនអន្តោប្រវេសន៍។

២. ការបណ្តុះបណ្តាល និងការអប់រំ

*ក. បុគ្គលិកកំពង់ផែ*

អភិវឌ្ឍន៍ជំនាញ ចំណេះដឹង និងការអនុវត្តប្រកបដោយសមភាព ភាពចំរុះ និងការបញ្ចូលគ្នារបស់បុគ្គលិកកំពង់ផែ ជាពិសេសសមាជិកនៃក្រុមអន្តរអង្គភាព ដើម្បីកាត់បន្ថយផលប៉ះពាល់ទៅលើសហគមន៍ដែលបណ្តាលមកពីដំណើរការរបស់កំពង់ផែ។ បណ្តុះបណ្តាលបុគ្គលិកកំពង់ផែអំពីការអនុវត្តល្អៗមួយចំនួន ដូចជាការចូលរួមរបស់សហគមន៍ប្រកបដោយសមភាព ការចូលរួមលើកតម្លៃសង្គម សាមគ្គីភាពរបស់សហគមន៍ជ្រលងភ្នំ*ឌូវ៉ាមីស្ស*។

*ខ. សហគមន៍*

ផ្តល់ការបណ្តុះបណ្តាលទៀងទាត់ដល់សហគមន៍លើបេសកម្ម ប្រតិបត្តិការរបស់កំពង់ផែ កម្មវិធី និងប្រធានបទផ្សេងៗ ដែលទាក់ទងនឹងការកសាងសមត្ថភាព ការសម្រេចចិត្តរួមគ្នា និតិវិធីនៃការបញ្ចេញមតិជាសាធារណៈ កាលវិភាគកំណត់នៃគម្រោង និងដំណើរការពិនិត្យជាសាធារណៈ។ រៀបចំសិក្ខាសាលាបណ្តុះ បណ្តាលដែលគាំទ្រដល់សកម្មភាពរបស់កម្មវិធីសមភាពរបស់សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* (DVCEP) ដូចជាការសម្របសម្រួល ការគ្រប់គ្រងគម្រោង និងការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ។

៣. ការចូលរួមរបស់សហគមន៍

ត្រួតពិនិត្យគោលនយោបាយ ការអនុវត្តន៍ និងដំណើរការរបស់កំពង់ផែ ដើម្បីធានាឲ្យមានការចូលរួមប្រកបដោយសមភាព។ ផ្តល់ឱកាសឲ្យមានចូលរួមពីសហគមន៍ ដើម្បីសម្រួលដល់ការសម្រេចចិត្តរួមគ្នា និងការចូលរួមក្នុងដំណើរការរបស់កំពង់ផែ។ រៀបចំព្រឹត្តិការណ៍ជាសាធារណៈ ដើម្បីឲ្យសហគមន៍អាចទទួលបានចំណេះដឹង បទពិសោធន៍ និងការយល់ដឹងអំពីដំណើរការ និងអភិបាលកិច្ចរបស់កំពង់ផែ ដូចជាការធ្វើដំណើរកំសាន្តលើទូកតាមដងទន្លេ*ឌូវ៉ាមីស្ស* ដែលមានការពន្យល់ជាពហុភាសា ព្រមទាំង

ព្រឹត្តិការណ៍ផ្សេងៗដែលរៀបចំដោយសហគមន៍ រួមមានពិធីបុណ្យប្រចាំឆ្នាំតាមដងទន្លេ *ឌូវ៉ាមីស្ស*។ រៀបចំកម្មវិធីចូលមើលដោយសេរីនៅក្នុងបរិវេណកំពង់ផែ និង រៀបចំកិច្ចប្រជុំគណៈកម្មាការនៅកន្លែងជួបជុំរបស់សហគមន៍។ រៀបចំឲ្យមានការចូលរួមពីផ្នែកថែរក្សា ផ្នែកសន្តិសុខ និងអង្គភាពនគរបាល ក្នុងកម្មវិធីដែលសាងទំនាក់ទំនងជាមួយនឹងសហគមន៍ និងទទួលបានការទុកចិត្ត ដើម្បីបង្កើនសុវត្ថិភាពនៅបរិវេណរបស់កំពង់ផែ។

៤. <u>មតិយោបល់របស់សហគមន៍</u>

ចាត់តាំងក្រុមការងារសកម្មកំពង់ផែរបស់សហគមន៍ (PCAT) ជាក្រុមអ្នកផ្តល់ប្រឹក្សាលើបញ្ហាយុត្តិធម៌នៅក្នុងសង្គម ដែលតំណាងឲ្យសម្លេងសហគមន៍ និងទទួលជំនួយផ្ទាល់ពី DVCEP។ ត្រូវមានការចូលរួមពីសហគមន៍ប្រកបដោយសមភាព ដើម្បីពិនិត្យគម្រោងទាំងឡាយណាដែលដឹកនាំដោយកំពង់ផែ ឬការកែលម្អ និងការផ្លាស់ប្តូរ ដែលប៉ះពាល់ដល់សហគមន៍។ ស្នើសុំ និងបញ្ចូលមតិយោបល់របស់សហគមន៍ ដោយប្រើការអនុវត្តល្អៗក្នុងការចូលរួមប្រកបដោយសមភាព។

៥. <u>កិច្ចសហការអន្តរភ្នាក់ងារ</u>

យើងចាំបាច់ត្រូវមានកិច្ចសហការរវាងភ្នាក់ងារសាធារណៈ និងស្ថាប័នផ្សេងៗ ព្រមទាំងដៃគូឧស្សាហកម្ម ដើម្បីដោះស្រាយបញ្ហារបស់សហគមន៍ និងបង្កើតឱកាសដែលគាំទ្រដល់គម្រោងផែនការមួយរយឆ្នាំរបស់កំពង់ផែ (Port's Century Agenda)។ ធ្វើការជាមួយនឹងភាគីពាក់ព័ន្ធដទៃទៀត ដូចជាក្រុមការងារអន្តរអង្គភាពរបស់*ឌូវ៉ាមីស្សវ៉ាឡេ* ដើម្បីស្វែងរកឱកាសក្នុងការសម្របសម្រួល និងប្រើប្រាស់ធនធានដែលមានឲ្យអស់លទ្ធភាព។ យោងតាមសេចក្តីសម្រេចលេខ៣១៥៦៧ របស់ក្រុង*ស៊ីអេថល* និងពាក្យស្នើសុំលេខ២០១៥-០១៦៧ របស់*យើងខោនធី* ត្រូវស្វែងរកលទ្ធភាពនៃជំនួយរបស់ អន្តរស្ថាប័ន ដើម្បីគាំទ្រដល់ការចូលរួមដោយស្មើភាពគ្នារបស់សហគមន៍នៅក្នុងសេដ្ឋកិច្ចថ្នាក់តំបន់។

៦. <u>លទ្ធផលបានមកពីបកស្រាយ និងវិភាគទិន្នន័យ</u>

ធ្វើការវិភាគមូលហេតុ ដើម្បីស្វែងយល់ពីឱកាស និងតម្រូវការរបស់កម្មវិធីសមភាពនៃសហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* (DVCEP)។ ធ្វើការជាមួយសហគមន៍ ក្នុងការប្រមូល និងវាយតម្លៃទិន្នន័យបែបបរិមាណ វិស័យ (quantitative) និងគុណវិស័យ (qualitative) ដើម្បីផ្សព្វផ្សាយព័ត៌មានដល់DVCEP អំពីការសម្រេចចិត្តផ្សេងៗ។ ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកកំពង់ផែ ឲ្យទទួលបានជំនាញក្នុងការប្រមូល និងវិភាគទិន្នន័យបែបវិភាគ (disaggregated data) ដើម្បីស្វែងយល់ពីបញ្ហាប្រឈមមុខ ហើយស្វែង

រកដំណោះស្រាយ និង តាមដានវឌ្ឍនភាពនៃទិន្នន័យនេះ។ ពិចារណាលើទិន្នន័យថ្មីៗ និងសិក្សាស្វែងយល់ពីបញ្ហាសមភាព ដើម្បីផ្តល់ពត៌មានដល់កម្មវិធីអំពីការសម្រេចចិត្ត ដូចជាផែនទីផ្សេងៗ អំពីវិសមភាពនៃបញ្ហាសុខភាពសហគមន៍នៅរដ្ឋ*វ៉ាស៊ីនតោន* (Washington Environmental Health Disparities Map)

## គ. គោលដៅទី២៖ សហគមន៍ និងបរិស្ថានប្រកបដោយសុខភាពល្អ

កំពង់ផែត្រូវដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ និងកត្តាប៉ះពាល់បរិស្ថានផ្សេងៗទៀត ដែលជះឥទ្ធិពលដល់សុខភាពសហគមន៍។ កម្មវិធីសមភាពនៃសហគមន៍ *ឌូវ៉ាមីស្សវ៉ាឡេ* (DVCEP) នឹងបង្កើនកិច្ចសហការជាមួយនឹងសហគមន៍លើសកម្មភាពដែលផ្តល់ជាប្រយោជន៍ដល់ភាគីពាក់ព័ន្ធទាំងអស់។ សកម្មភាពទាំងនោះរបស់កំពង់ផែ រួមមាន៖

១. <u>ការប្រែប្រួលអាកាសធាតុ</u>

ធ្វើការសហការជាមួយភ្នាក់ងារសាធារណៈ ដៃគូឧហ្សាហកម្ម ស្ថាប័នផ្សេងៗ និងសហគមន៍ ដើម្បីចូលរួមក្នុងផែនការក្នុងតំបន់ ក្នុងការដោះស្រាយផលប៉ះពាល់បណ្តាលពីការប្រែប្រួលអាកាសធាតុ។ ធ្វើការជាមួយសហគមន៍ ដើម្បីលើកម្ពស់ការយល់ដឹង និងអនុវត្តដំណោះស្រាយក្នុងការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ដែលបណ្តាលមកពីឧស្សាហកម្មដែលទាក់ទងនឹងកំពង់ផែ ដូចជានាវាចរណ៍ អាកាសចរណ៍ ពាណិជ្ជកម្ម ទេសចរណ៍ និងការដឹកជញ្ជូន។ បន្តកិច្ចខិតខំប្រឹងប្រែងរបស់កំពង់ផែ*ស៊ីអេថល* ដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (Greenhouse Gases)។ ប្រើប្រាស់កំពង់ផែ*ស៊ីអេថល* ឲ្យអស់លទ្ធភាព និងទៅដល់គោលដៅក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ របស់សម្ព័ន្ធកំពង់ផែសមុទ្រភាគពាយ័ព្យ (The Northwest Seaport Alliance Greenhouse Gases) ដើម្បីផ្តល់ជាអនុសាសន៍មួយចំនួនក្នុងការកាត់បន្ថយឧស្ម័នពុល។ សហការជាមួយនឹងភ្នាក់ងារសាធារណៈ និងស្ថាប័នដទៃទៀត ដើម្បីជានាដល់ការវិនិយោគ ដែលលើកកម្ពស់អំពីការទប់ទល់នៃប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយឧស្ម័នពុល។ ធ្វើការជាមួយនឹងសហគមន៍ក្នុងការជំរុញឲ្យមានការបង្កើតថ្មី ឬភាពច្នៃប្រឌិត ដើម្បីដកឧស្ម័នកាបូនិច (carbon sequestration) និងគម្រោងផលិតថាមពលកកើតឡើងវិញ (renewable energy) នៅតាមតំបន់ឧស្សាហកម្មកំពង់ផែ ដូចជាគម្រោងឧស្ម័នកាបូនខៀវ (Blue Carbon Projects) និងការតម្លើងបន្ទះសូឡានៅតាមស្ថានីយកំពង់ផែងនានា។

២. <u>គុណភាពខ្យល់</u>

សម្ព័ន្ធកំពង់ផែសមុទ្រភាគពាយ័ព្យ (NWSA) អនុវត្តកម្មវិធីដើម្បីកាត់បន្ថយការបំភាយឧស្ម័នពុលពីកំពង់ផែ និងសកម្មភាពផ្សេងៗរបស់ម្ចាស់អាជីវកម្មដែលធ្វើប៉ះពាល់ដល់សុខភាពរបស់សហគមន៍ ដូចជាកម្មវិធីឡានដឹកទំនិញដែលមិនបំភាយផ្សែងពុល (Clean Truck Program) របស់ NWSA និងគម្រោងពង្រីកស្ថានីយឡានដឹកទំនិញក្នុងតំបន់កនាពេលអនាគត។ សហការជាមួយនឹង NWSA និងភ្នាក់ងារសាធារណៈ ភាគីពាក់ព័ន្ធ និងស្ថាប័នដទៃទៀត ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានប្រកបដោយសមភាពចំពោះការកែលម្អគុណភាពខ្យល់។ សហការជាមួយភាគីពាក់ព័ន្ធ ដើម្បីផ្តល់ការអប់រំ ការបណ្តុះបណ្តាល និងធនធានផ្សេងៗ ដែលជួយកសាងសមត្ថភាពសហគមន៍ ក្នុងការចាត់វិធានការណ៍លើគុណភាពខ្យល់។ លើកកម្ពស់គម្រោងវិទ្យាសាស្រ្តរបស់សហគមន៍ដែលជួយកំណត់បញ្ហាចម្បងរបស់សហគមន៍ ដើម្បីដោះស្រាយបញ្ហាផលប៉ះពាល់បណ្តាលមកពីគុណភាពខ្យល់នៅតំបន់កំពង់ផែ។ ជំរុញឲ្យមានការចូលរួមពីសហគមន៍ប្រកបដោយសមភាព នៅក្នុងការចុះបញ្ជីខ្យល់បរិសុទ្ធរបស់កំពង់ផែភាគពាយ័ព្យ (Northwest Port Clean Air Inventory) និងយុទ្ធសាស្រ្តថ្មីៗ ព្រមទាំងការអនុវត្តផ្សេងៗនាពេលបច្ចុប្បន្ន។ ធ្វើការជាមួយនឹងដៃគូឧស្សាហកម្ម របស់សហគមន៍និងភ្នាក់ងារសាធារណៈដទៃទៀត ដើម្បីផ្តល់ភាពងាយស្រួលក្នុងការអនុវត្តន៍ប្រកបដោយសមភាព ការប្រើប្រាស់ទិន្នន័យបែបវិភាគ និងដំណើរការក្នុងការសម្រេចចិត្តរួមគ្នា ចំពោះបញ្ហាគុណភាពខ្យល់។

៣. <u>ការធ្វើចរាចរណ៍របស់ឡានដឹកទំនិញ</u>

ដើម្បីលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងរបស់សម្ព័ន្ធកំពង់ផែសមុទ្រភាគពាយ័ព្យ (NWSA) យើងត្រូវសហការជាមួយនឹងសហគមន៍ ម្ចាស់អាជីវកម្មនៅតាមកំពង់ផែ អ្នកបើកឡានដឹកទំនិញ សេវាកម្មអាជីវកម្ម និងភ្នាក់ងារសាធារណៈដទៃទៀត ដើម្បីផលប៉ះពាល់ដែលបណ្តាលមកពីការដឹកជញ្ជូនទំនិញ។ ប្រើប្រាស់ក្របខណ្ឌការងារប្រកបដោយសមភាព ដើម្បីកែប្រែគោលការណ៍ដឹកជញ្ជូនទំនិញមកដាក់ក្នុងឃ្លាំង និងការអនុវត្តន៍ចំពោះការដឹកទំនិញ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសាធារណៈ ផ្លូវបើកបរឡានដឹកទំនិញ ការបណ្តុះបណ្តាលអ្នកបើកបរ ចំណតឡានដឹកទំនិញ ការថែរក្សាផ្លូវថ្នល់ និងការអនុវត្តន៍ច្បាប់ចរាចរណ៍។ ធ្វើការជាមួយនឹងទីភ្នាក់ងារសាធារណៈ រួមមាន NWSA និងភាគីពាក់ព័ន្ធសំខាន់ៗដទៃទៀតដូចជាអ្នកដែលរងផលប៉ះពាល់ជាងគេដើម្បីដោះស្រាយរាល់បញ្ហាដឹកជញ្ជូនទំនិញនៅក្នុងតំបន់ និងជំរុញឲ្យសហគមន៍ចូលរួមចំណែកក្នុងការសម្រេចចិត្តដែលទាក់ទងនឹងការកែលម្អផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធ ចំណតរថយន្ត ការតម្រង់ជួរ ការសំចតតាមផ្លូវ និងផលប៉ះពាល់នៃការដឹកជញ្ជូនទំនិញដទៃទៀត។

៤. ផលប៉ះពាល់ដោយសំឡេង

ដោយមានការសម្របសម្រួលជាមួយនឹង NWSA យើងត្រូវសហការជាមួយនឹងសហគមន៍ ភ្នាក់ងារសាធារណៈ និងភាគីពាក់ព័ន្ធសំខាន់ដទៃទៀត ចំពោះការកាត់បន្ថយផលប៉ះពាល់ដោយសំឡេងដែលទាក់ទងនឹងសកម្មភាពផ្សេងៗរបស់កំពង់ផែ។ ធ្វើការជាមួយនឹងភ្នាក់ងារសាធារណៈដទៃទៀត ដើម្បីស្វែងរកការចែកចាយ និងការវិនិយោគប្រកបដោយសមភាព។

៥. សួនឧទ្យានសាធារណៈ និងតំបន់បៃតង

រៀបចំបរិវេណកំពង់ផែនៅតាមដងទន្លេ*ឌូវ៉ាមីស្ស* ឲ្យកាន់ស្អាត ដោយបង្កើត និងថែរក្សាលំនៅដ្ឋានតាមដងទន្លេ តំបន់បៃតង កន្លែងកំសាន្ត និងផ្លូវចូលទៅកាន់ទន្លេ។ គាំទ្រដល់ការងារដែល សហគមន៍កំពុងធ្វើ ដើម្បីរៀបចំ និងកែលម្អតំបន់បៃតងមួយចំនួន ដូចជាឧទ្យាន Gateway Park North និង 12th Ave South/South Elmgrove Street និងសហការជាមួយសហគមន៍ ដើម្បីបង្កើនការប្រើប្រាស់តំបន់បៃតងរបស់កំពង់ផែ។ រៀបចំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវសម្រាប់ជិះកង់កំសាន្ត ភ្ជាប់ផ្លូវថ្មើរជើង និងរក្សាសុវត្ថិភាពនៅបរិវេណកំពង់ផែ។ លើកទឹកចិត្តដល់ឧស្សាហកម្មដែលទាក់ទងនឹងកំពង់ផែ និងភ្នាក់ងារសាធារណៈដទៃទៀត ដើម្បីកែលម្អ និងរក្សាសុវត្ថិភាពរបស់អ្នកថ្មើរជើង និងអ្នកជិះកង់ នៅតាមបណ្តោយផ្លូវទៅកាន់កំពង់ផែដែលមានការធ្វើចរាចរច្រើន ។ រៀបចំហេដ្ឋារចនាសម្ព័ន្ធបៃតងដោយមានការដាំរុក្ខជាតិនៅតាមជញ្ជាំងនៃបរិវេណកំពង់ផែ។

៦. គុណភាពទឹក

បន្តការស្វែងរកការបញ្ជាក់ពីសុវត្ថិភាពត្រីសាល់មិន នៅតាមឧទ្យានទាំងអស់ និងនៅតាមទីតាំងផ្លូវសាធារណៈផ្សេងៗរបស់កំពង់ផែ។ ផ្សព្វផ្សាយគម្រោងវិទ្យាសាស្ត្ររបស់សហគមន៍ ដែលជួយដល់ការកំណត់បញ្ហាចាំបាច់របស់សហគមន៍ ដើម្បីដោះស្រាយផលប៉ះពាល់ទៅលើគុណភាពទឹកនៅតាមកំពង់ផែ។ សហការជាមួយនឹងសហគមន៍ ភ្នាក់ងារសាធារណៈ និងភាគីពាក់ព័ន្ធសំខាន់ដទៃទៀត លើកម្មវិធីអប់រំអំពីផ្ទៃទឹកនៃតំបន់*ឌូវ៉ាមីស្ស* និងកម្មវិធីកែលម្អ។ អនុវត្តការរៀបចំហេដ្ឋារចនា សម្ព័ន្ធគ្រប់គ្រងទឹកភ្លៀងនៅតាមតំបន់បៃតងនៃបរិវេណកំពង់ផែ។ សហការជាមួយនឹងសម្ព័ន្ធកំពង់ផែសមុទ្រភាគពាយ័ព្យ (NWSA)ស្វែងរកដំណោះស្រាយក្នុងការកែលម្អគុណភាពទឹក។ ផ្សព្វផ្សាយ ពត៌មានជាមួយនឹងដៃគូឧស្សាហកម្ម សមុទ្រនិងនេសាទ ដើម្បីគាំទ្រដល់សេដ្ឋកិច្ចនៃអាហារសមុទ្រ និងនិរន្តរភាព។

## ឃ. គោលដៅទី៣៖ ភាពសម្បូរបែបចូលរួមក្នុងតំបន់

កំពង់ផែត្រូវគាំទ្រដល់ដំណោះស្រាយនៃការប្រឆាំងនឹងការផ្លាស់ប្តូរទីតាំង ដែលអាចឲ្យសហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* ធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង តាមរយៈការទទួលបាននៃការបណ្តុះបណ្តាល ការងារការតម្រង់ទិសសម្រាប់អាជីពការងារ និងឱកាសសេដ្ឋកិច្ចដែលទាក់ទងនឹងកំពង់ផែ ប្រកបដោយភាពស្មើគ្នា។ កម្មវិធីសមភាពនៃសហគមន៍ជ្រលងភ្នំ*ឌូវ៉ាមីស្ស* (DVCEP) នឹងជំរុញកិច្ចសហការជាមួយនឹងសហគមន៍ ចំពោះសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលផ្តល់ជាប្រយោជន៍ដល់ភាគីពាក់ព័ន្ធទាំងអស់ឲ្យបានច្រើនបំផុត។ សកម្មភាពផ្សេងៗរបស់កំពង់ផែរួមមាន៖

១. <u>ការជ្រើសរើស និងការរក្សាទុកបុគ្គលិក</u>

បង្កើនការទទួលបានការងារធ្វើ និងការស្វែងរកការងារប្រកបដោយសមភាព។ ផ្សព្វផ្សាយព័ត៌មានអំពីឱកាសរកការងារនៅកំពង់ផែ និងក្រុមហ៊ុនឧស្សាហកម្មផ្សេងៗដែលទាក់ទងនឹងកំពង់ផែ។ បន្តគោលនយោបាយជួលបុគ្គលិកអាទិភាពរបស់កំពង់ផែ (Port's Priority Hire Policy) ដើម្បីបង្កើនការទទួលបានការងារធ្វើ ការបណ្តុះបណ្តាល និងការហ្វឹកហាត់ការងារ។ ជម្រុញឲ្យមានកន្លែងធ្វើការ ដែលមានសុវត្ថិភាព និងធ្វើការរួមគ្នា ដែលធានាដល់ការរក្សាទុកបុគ្គលិក ការអភិវឌ្ឍសមត្ថភាពការងារ ការតម្លើងដំណែងនិយោជិតដែលមានដើមកំណើតជាជនបរទេស និងក្រុមជាតិសាសន៍ដែលគេមិនសូវស្គាល់ដទៃទៀត នៅកំពង់ផែ។ បង្កើតឲ្យមានអន្តរទីភ្នាក់ងារផ្តល់ព័ត៌មានការងារ ហើយនិងបង្កើតឲ្យមានមជ្ឈមណ្ឌលបណ្តុះបណ្តាល ដើម្បីលើកកម្ពស់អាជីពការងារដែលទាក់ទងនឹងកំពង់ផែ។

២. <u>ការអភិវឌ្ឍន៍កម្លាំងពលកម្មយុវជន</u>

វិនិយោគលើកម្មវិធីអភិវឌ្ឍន៍កម្លាំងពលកម្មយុវជន ដោយផ្តល់ឱកាសដល់យុវជននៅក្នុងសហគមន៍ទទួលបានការតម្រង់ទិសសម្រាប់អាជីពការងារ នៅតាមកំពង់ផែ។ ធ្វើការផ្សព្វផ្សាយអំពីការបណ្តុះបណ្តាលនៃការកសាងជំនាញវិជ្ជាជីវៈដល់យុវជន ដូចជាសិក្ខាសាលាបង្រៀនពីរបៀបរៀបចំប្រវត្តិរូបសង្ខេបជាដើម។ គាំទ្រការអភិវឌ្ឍន៍សមត្ថភាពជំនាញ នៅតាមក្រុមហ៊ុនឧស្សាហកម្មនានានៃកំពង់ផែ ដូចជាកម្មវិធីផ្តល់ប្រឹក្សា។ ផ្តល់ឱកាសដល់យុវជនចូលរួមក្នុងការធ្វើពាណិជ្ជកម្ម និងសកម្មភាពដកបទពិសោធន៍។ សហការជាមួយនឹងកម្មវិធីអប់រំដែលផ្តល់ឱកាសដល់យុវជនចុះសិក្សាស្វែងយល់ នៅតាមក្រុមហ៊ុនឧស្សាហកម្មនានានៃកំពង់ផែ។ លើកកម្ពស់សកម្មភាពចូលរួមសហគមន៍ដឹកនាំដោយយុវជន។ រក្សានិរន្តភាពនៃកម្មវិធីចុះកម្មសិក្សាការងារដែលផ្តល់ប្រាក់ខែខ្ពស់សម្រាប់យុវជន នៅកំពង់ផែ។

៣. <u>ការអភិវឌ្ឍន៍កម្លាំងពលកម្មនិតិជន</u>

វិនិយោគលើកម្មវិធីអភិវឌ្ឍន៍កម្លាំងពលកម្មនិតិជន ដោយផ្តល់ឱកាសដល់សមាជិកសហគមន៍នៅក្នុងសហគមន៍ទទួលបានការតម្រង់ទិសសម្រាប់អាជីពការងារ នៅតាមកំពង់ផែ។ ពង្រីកឱកាសអប់រំ និងផ្តល់នូវប្រាក់កម្រៃការបណ្តុះបណ្តាលការងារ។ គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ ក្នុងការលើកស្ទួយកម្មវិធីតម្រង់ទិសសម្រាប់អាជីពការងារ នៅកំពង់ផែ និងនៅតាមក្រុមហ៊ុនឧស្សាហកម្មនានានៃកំពង់ផែ ដូចជាកម្មវិធីគ្រប់គ្រងថែរក្សាជម្រកសត្វនៅតាមដែនសមុទ្រ។ លើកកម្ពស់ការផ្តល់ការងារសម្រាប់អតីតយុទ្ធជន និងឱកាសបណ្តុះបណ្តាល និងការជ្រើសរើសបុគ្គលិក តាមរយៈពិពណ៌ការងារ។

៤. <u>ការអភិវឌ្ឍន៍សេដ្ឋកិច្ច</u>

ជួយសហគមន៍ ក្នុងការកំណត់ និងអនុវត្តកិច្ចការអាទិភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយសម្របសម្រួលផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចដឹកនាំដោយសហគមន៍ និងការកសាងសមត្ថភាពក្រុមការងារសហគមន៍។ ជួយសហគមន៍ ក្នុងការដឹកនាំ និងអនុវត្តផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច។ លើកស្ទួយកិច្ចសហប្រតិបត្តិការអន្តរទីភ្នាក់ងារ និងអាជីវកម្មរបស់សហគមន៍ ដើម្បីបង្កើនឱកាសសេដ្ឋកិច្ច និងឱកាសការងារដែលប្រើកម្លាំងកាយសម្រាប់សហគមន៍។ បង្កើតបណ្តាញធនធានសម្រាប់អាជីវកម្ម និងសហគ្រិន ដែលអាចគាំទ្រដល់ការទប់ទល់នឹងការបង្ខំឲ្យផ្លាស់ប្តូរលំនៅដ្ឋាន។ បណ្តុះឲ្យមានការបណ្តាក់ទុនអាជីវកម្មថ្មីទៀត ដោយគាំទ្រការធ្វើជាម្ចាស់អាជីវកម្ម និងការផ្តល់អំណាចដល់បុគ្គលនៅក្នុងសហគមន៍ដែលចង់ក្លាយជាសហគ្រិន។ ផ្តល់ព័ត៌មានអំពីឱកាសនៃការលក់ដូ និងការធ្វើអាជីកម្ម នៅកំពង់ផែ។

៥. <u>កិច្ចគាំទ្រដល់សេដ្ឋកិច្ចប្រកបដោយសមភាព ចម្រុះ និងការទទួលខុសត្រូវផ្នែកបរិស្ថាន</u>

លើកទឹកចិត្តដល់ក្រុមហ៊ុនឧស្សាហកម្មនៅតាមកំពង់ផែនៃដងទន្លេ *ឌូវ៉ាមីស្ស* ដោយគាំទ្រដល់លើកកម្ពស់សុខមាលភាពសង្គម និងសមិទ្ធផលរបស់សហគមន៍ប្រកបដោយសមភាព។ ជានាថាទិសដៅយុទ្ធសាស្ត្ររបស់កំពង់ផែ ក្នុងការថែរក្សាដីតំបន់ឧស្សាហកម្ម រួមមានការលើកកម្ពស់និរន្តរភាព និងភាពសម្បូរធូរជានៃសេដ្ឋកិច្ចសម្រាប់សហគមន៍។ បន្តការស្រាវជ្រាវ និងការអភិវឌ្ឍន៍ទីផ្សារនៃបច្ចេកវិទ្យាថ្មីៗ ព្រមទាំងប្រភពធនធានថាមពលកកើតឡើងវិញ ដូចជាប្រេងឥន្ធនៈអាកាសចរប្រកបដោយនិរន្តរភាព ដើម្បីកាត់បន្ថយការពឹងផ្អែកលើប្រេងឥន្ធនៈដែលបានមកពីការជុតផូស៊ីល នៅក្នុងតំបន់។ រៀបចំការបណ្តុះបណ្តាលកម្លាំងពលកម្ម និងកម្មវិធីតម្រង់ទិសសម្រាប់អាជីពការងារ ដែលនាំឲ្យក្រុមហ៊ុនឧស្សាហកម្មទាក់ទងនឹងកំពង់ផែពង្រឹងតំបន់សេដ្ឋកិច្ចបៃតងនៅក្នុងតំបន់។

## ផ្នែកទី៦៖ ការវាយតម្លៃកម្មវិធី

ក. នាយកប្រតិបត្តិ ឬ ប្រតិភូ ត្រូវបង្កើតវិធានការណ៍គ្រប់គ្រង និងប្រព័ន្ធវាស់វែង ដោយសហការជាមួយក្រុមការងារអន្តរអង្គភាព (IDT) និងក្រុមការងារសេកម្មសហគមន៍របស់កំពង់ផែ (PCAT) ដើម្បីវាយតម្លៃកម្មវិធីសមភាពរបស់សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* (DVCEP)។ វិធានការ និងប្រព័ន្ធវាស់វែង ដែលកំណត់ក្នុងយុទ្ធសាស្ត្រនេះត្រូវបញ្ចូលទាំងសូចនាករបែបបរិមាណវិស័យ និងបែបគុណវិស័យ (quantitative and qualitative indicators) ដែលចង្អុលបង្ហាញពីគោលដៅដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងនេះ។ ឧទាហរណ៍៖

១. សូចនាករបែបបរិមាណវិស័យរួមមាន៖ ថ្លៃចំណាយនៃគម្រោង ពេលវេលាបញ្ចប់នៃគម្រោង អត្រានៃការបញ្ចប់ការហ្វឹកហាត់ការងាររបស់យុវជននៃតំបន់ជ្រលងឌូវ៉ាមីស្ស និងរយៈពេលដែលចំណាយក្នុងការរៀបចំកម្មវិធីជ្រើសរើសបុគ្គលិកកំពង់ផែ នៅក្នុងសហគមន៍។
២. សូចនាករបែបគុណវិស័យរួមមាន៖ ការរាប់ទាំងមតិយោបល់របស់សហគមន៍ និងក្រុមការងារ PCAT ក្នុងការសម្រេចចិត្តរបស់កំពង់ផែ បទពិសោធន៍នៃការជម្រុញការចូលរួមដោយបុគ្គលិកកំពង់ផែ បង្កើនការយល់ដឹងអំពីកិច្ចខិតខំប្រឹងប្រែងប្រកបដោយសមភាព ភាពចម្រុះ និងការខិតខំរួមគ្នា របស់បុគ្គលិកកំពង់ផែ និងសហគមន៍។
៣. ការវាយតម្លៃកម្មវិធី ផ្ដោតលើទិន្នន័យជំរឿនប្រជាជន ដើម្បីកំណត់អត្តសញ្ញាណឲ្យកាន់តែច្បាស់ថាតើបុគ្គលណា ទទួលបានអត្ថប្រយោជន៍ ឬក៏មិនទទួលបាន ពីប្រភពធនធាន និងកម្មវិធីរបស់កំពង់ផែ។ បុគ្គលិកទាំងអស់ត្រូវមានភារកិច្ចប្រមូលទិន្នន័យឲ្យបានច្រើន តាមដែលអាចធ្វើបាន។

ខ. នាយកប្រតិបត្តិ ឬ ប្រតិភូ សហការជាមួយនឹងក្រុមការងារសេកម្មសហគមន៍របស់កំពង់ផែ (PCAT) ត្រូវរៀបចំផែនការវាយតម្លៃដែលរៀបរាប់ពីរបៀបត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីសមភាពរបស់សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* (DVCEP) ព្រមទាំងរបៀបប្រើប្រាស់លទ្ធផលដែលបានមកពីការវាយតម្លៃ សម្រាប់ការកែលម្អ និងការសម្រេចចិត្តនៃកម្មវិធីនេះ។
គ. នាយកប្រតិបត្តិ ឬ ប្រតិភូ សហការជាមួយនឹងក្រុមការងារសេកម្មសហគមន៍របស់កំពង់ផែ (PCAT) ត្រូវ ផ្តល់របាយការណ៍ប្រចាំឆ្នាំ ដើម្បីផ្តល់ព័ត៌មានថ្មីៗដល់គណៈកម្មាការកំពង់ផែ ចំពោះការអនុវត្តន៍កម្មវិធី DVCEPកាលពីឆ្នាំកន្លងទៅ។
របាយការណ៍នេះ មានដូចខាងក្រោម៖

១. ការពិពណ៌នាអំពីសកម្មភាពដែលបានអនុវត្ត។
២. ការពិពណ៌នាអំពីគោលដៅ និងសមិទ្ធផលប្រចាំឆ្នាំរបស់កម្មវិធី DVCEP។

៣. ការពិណ៌នាអំពីបញ្ហានិងឧបសគ្គនានាដែលភាគីពាក់ព័ន្ធចូលរួមកំពុងជួបប្រទះ និងចាត់វិធានការដើម្បីដោះស្រាយបញ្ហាទាំងនោះ។

៤. ការពិពណ៌នាអំពីមេរៀនដែលបានសិក្សា និងការអនុវត្តល្អៗ។

៥. ការពិពណ៌នាអំពីយុទ្ធសាស្ត្រ និងឧបករណ៍ដែលបានប្រើ។

៦. ការវិភាគប្រភពធនធាន និងភាពជាដៃគូ ដែលត្រូវការដើម្បីជួយដល់ការរៀបចំយុទ្ធសាស្ត្រឲ្យកាន់តែប្រសើរ។

៧. អនុសាសន៍សម្រាប់យុទ្ធសាស្ត្រថ្មីៗ ដើម្បីសម្រេចគោលដៅកម្មវិធី DVCEP។

ឃ. នាយកប្រតិបត្តិ ឬ ប្រតិភូ សហការជាមួយនឹងក្រុមការងារសកម្មសហគមន៍របស់កំពង់ផែ (PCAT) ត្រូវដឹកនាំបុគ្គលិកសំខាន់ៗរបស់កំពង់ផែ ដើម្បីផ្តល់ព័ត៌មានប្រចាំឆ្នាំដល់សហគមន៍ ដោយប្រើប្រាស់ការអនុវត្តល្អៗនៃការចូលរួមប្រកបដោយសមភាព។

ង. នាយកប្រតិបត្តិ ឬ ប្រតិភូ ត្រូវពិនិត្យមើលលទ្ធផលរបស់កម្មវិធី DVCEP ជារៀងរាល់ឆ្នាំ ដើម្បីបញ្ជាក់ថាតើ DVCEP បានបំពេញតាមគោលដៅកំណត់នៅកិច្ចព្រមព្រៀង ដែរឬទេ។

ច. នាយកប្រតិបត្តិ ឬ ប្រតិភូ ត្រូវផ្តល់សិទ្ធិដល់បុគ្គលិកសំខាន់ៗរបស់កំពង់ផែក្នុងការកែប្រែការអនុវត្តផ្សេងៗ ដើម្បីធានាបានថា បុគ្គលិកកំពង់ផែគោរពតាមខ្លឹមសារកំណត់ក្នុងកិច្ចព្រមព្រៀងនេះ។

## ឯកសារភ្ជាប់ A៖ គំរូនៃផែនការការងារឆ្នាំ២០២០

### ក. សេចក្តីផ្តើម

នៅខែកក្កដា ឆ្នាំ២០១៩ ក្រុមការងារសកម្មសហគមន៍របស់កំពង់ផែ (PCAT) បានកោះប្រជុំដើម្បីកំណត់អាទិភាពមូលដ្ឋានចំពោះសកម្មភាពទាំងអស់ ដែលបម្រើឲ្យកម្មវិធីសមភាពរបស់សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* (DVCEP) សម្រាប់ឆ្នាំ២០២០។ គេប្រើប្រាស់គម្រោងខាងក្រោមនេះជាគំរូសម្រាប់ការអភិវឌ្ឍន៍ផែនការការងារប្រចាំឆ្នាំ ហើយកាលបរិច្ឆេទខាងក្រោមនេះអាចមានការកែប្រែ។

### ខ. ភារកិច្ច និងធនធាន

ក្រុមការងារអន្តរអង្គភាព (IDT) មានអង្គភាពផ្សេងៗរបស់កំពង់ផែដែលផែនការការងាររបស់ពួកគេស្របនឹងវិស័យអាទិភាពខាងក្រោមនេះ។ នៅឆ្នាំ២០២០ អង្គភាពទាំងនោះមានដូចជា៖ ទំនាក់ទំនងខាងក្រៅ បរិស្ថាននិងនិរន្តរភាព អង្គភាពដែនសមុទ្រ/គ្រប់គ្រងដែនសមុទ្រ អាជ្ញាធរកំពង់ផែសមុទ្រភាគពាយ័ព្យ (NWSA) អភិវឌ្ឍន៍សេដ្ឋកិច្ច ធនធានមនុស្ស និងការិយាល័យសមភាព ភាពចម្រុះ និងកិច្ចការរួម។

### គ. ការអនុវត្តកិច្ចព្រមពៀងផលលាភរបស់សហគមន៍

យោងតាមការអនុម័ត្រកិច្ចព្រមព្រៀងរបស់គណៈកម្មការ បុគ្គលិកទាំងអស់ត្រូវគ្រប់គ្រងកម្មវិធី DVCEP ជាបីកម្រិតផ្សេងគ្នា៖

១. <u>កម្មវិធីសមភាពរបស់សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* (DVCEP)</u>

យុទ្ធសាស្រ្តគន្លឹះ៖ រៀបចំរចនាសម្ព័ន្ធសម្រាប់ការសម្រេចចិត្តរួមគ្នា តម្លាភាព ភាពជាអ្នកដឹកនាំ និងឥទ្ធិពលលើការរៀបចំ និងការវាយតម្លៃកម្មវិធី DVCEP និងគោលនយោបាយ និងការអនុវត្តរបស់កំពង់ផែ។

ក. នៅចុងបញ្ចប់នៃសំណួរទី១ (Q1) បណ្តុះបណ្តាលក្រុមការងារអន្តរអង្គភាព (IDT)។

ខ. នៅចុងបញ្ចប់នៃសំណួរទី២ (Q2) ជួយសម្របសម្រួលការប្រជុំរបស់ក្រុមការងារ IDT នៃសហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* ដែលផ្តោតលើការងារទំនាក់ទំនងខាងក្រៅ។

គ. បន្តការងាររៀបចំកម្មវិធីដែលកំពុងដំណើរការ (ដូចជាការផ្សព្វផ្សាយការចុះហ្វឹកហាត់ការងារនៅតាមវិទ្យាល័យ ពិធីបុណ្យទន្លេ *ឌូវ៉ាមីស្ស* កម្មវិធី *ឌូវ៉ាមីស្សអឺឡាយហ្វ* Duwamish Alive)។

ឃ. នៅចុងបញ្ចប់នៃសំណួរទី៣ (Q3) ធ្វើការជាមួយនឹងក្រុមការងារ PCAT សម្រាប់ផែនការយុទ្ធសាស្រ្តបីឆ្នាំ ផែនការការងារប្រចាំឆ្នាំ និងផែនការវាយតម្លៃ រួមមានវិធានការណ៍គ្រប់គ្រង និងប្រព័ន្ធវាស់វែង។

២. ការអភិវឌ្ឍន៍របស់ក្រុមងារ PCTA

យុទ្ធសាស្ត្រគន្លឹះ៖ គាំទ្រការរៀបចំរចនាសម្ព័ន្ធក្រុមការងារ PCAT ជាផ្លូវការ ការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ និងកិច្ចសហប្រតិបត្តិការជាមួយនឹងកំពង់ផែ។

ក. នៅចុងបញ្ចប់នៃសំណួរទី១ (Q1) គាំទ្រក្រុមការងារ PCAT ក្នុងការជ្រើសរើសសមាជិកភាព បង្កើនសមត្ថភាព និងជំនាញតាមរយៈការបណ្តុះបណ្តាល។

ខ. នៅចុងបញ្ចប់នៃសំណួរទី២ (Q២) គាំទ្រការបង្កើនការយល់ដឹងរបស់សហគមន៍អំពីថវិការកម្មវិធី និតិវិធីអភិបាលកិច្ច និងដំណើរការកិច្ចសន្យា។

គ. នៅចុងបញ្ចប់នៃសំណួរទី២ (Q២) គាំទ្រក្រុមការងារ PCAT ដើម្បីបញ្ចប់សេចក្តីព្រាងច្បាប់ និងរចនាសម្ព័ន្ធ និងកំណត់តួនាទី/អនុគណៈកម្មាធិការ ព្រមទាំងពិភាក្សាពីតម្រូវការសម្រាប់ភាពជាដៃគូ និងកិច្ចព្រមព្រៀមបន្ថែម។

ឃ. នៅចុងបញ្ចប់នៃសំណួរទី៤ (Q៤) ធ្វើការជាមួយក្រុមការងារ PCAT ដើម្បីអនុវត្តគម្រោងអាទិភាពរបស់ PCAT។

៣. គម្រោងអាទិភាពរបស់ PCAT

យុទ្ធសាស្ត្រគន្លឹះ៖ អនុវត្តន៍សកម្មភាពផ្សេងៗនៃកម្មវិធី ដើម្បីសម្រេចបានសមិទ្ធផលរបស់គម្រោង។ ដោះស្រាយដោយប្តេជ្ញា ភាពច្នៃប្រឌិត និងការយកចិត្តទុកដាក់លើភាពលម្អៀងដែលកើតមាន និងកំពុងកើតមាន ចំពោះការទទួលបានផលលាភរបស់កំពង់ផែ ដើម្បីកាត់បន្ថយការផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាជនក្នុងសហគមន៍។

គោលដៅទី១៖ ការកសាងសមត្ថភាពរបស់កំពង់ផែ និងសហគមន៍ សម្រាប់កិច្ចសហការបន្ត

ក. នៅចុងបញ្ចប់នៃសំណួរទី២ (Q2) ធ្វើការជាមួយនឹងក្រុមការងារអន្តរអង្គភាព (IDT) ដែលផ្តោត លើកិច្ចការទំនាក់ទំនងខាងក្រៅ ដើម្បីស្វែងរកឱកាសសម្រាប់ការសម្របសម្រួល និងការប្រើប្រាស់ធនធានដែលមានឲ្យអស់លទ្ធភាព។

ខ. នៅចុងបញ្ចប់នៃសំណួរទី៤ (Q4) រៀបចំដំណើរកំសាន្តលើទូកតាមដងទន្លេ *ឌូវ៉ាមីស្ស* ប្រចាំឆ្នាំលើកទី៣ ដែលមានការពន្យល់ជាពហុភាសា។

គោលដៅទី២៖ សហគមន៍ និងបរិស្ថានប្រកបដោយសុខភាពល្អ

ក. នៅចុងបញ្ចប់នៃសំណួរទី១ (Q1) បន្តកម្មវិធីគ្រប់គ្រងជំរកសត្វនៅតាមដែនសមុទ្ររបស់កំពង់ផែ។

ខ. នៅចុងបញ្ចប់នៃសំណួរទី៣ (Q3) បន្តគម្រោងអប់រំអំពីគុណភាពខ្យល់របស់សម្ព័ន្ធកំពង់ផែ សមុទ្រភាគពាយ័ព្យ NWSA ដោយមានការសម្របសម្រួលជាមួយនឹង យុទ្ធសាស្ត្រខ្យល់បរិសុទ្ធរបស់កំពង់ផែភាគពាយ័ព្យ (Northwest Ports Clean Air Strategy) និងកម្មវិធីខ្យល់ស្អាតនៃការរួមគ្នាសម្អាតទន្លេ *ឌូវ៉ាមីស្ស* (Duwamish River Cleanup Coalition's Clean Air Program)។

គ. នៅចុងបញ្ចប់នៃសំណួរទី៣ (Q3) បញ្ចប់ការសិក្សាផ្ទាល់ដល់ទីកន្លែង ដើម្បីវាយតម្លៃពីស្ថានភាពនៃចិញ្ចើមផ្លូវជិះកង់នៅក្នុងបរិវេណកំពង់ផែ។

ឃ. នៅចុងបញ្ចប់នៃសំណួរទី៤ (Q4) បញ្ចប់ការជួសជុលសំណង់ប្រាំងសមុទ្រនៅតំបន់ 8th Ave N/Gateway Park North។

ង. នៅចុងបញ្ចប់នៃសំណួរទី៤ (Q4) ផ្តល់វឌ្ឍនភាពនៃការជួសជុលប្រាំងសមុទ្រនៅ 12th Ave. South/South Elmgrove Street។

<u>គោលដៅទី៣៖ ភាពសម្បូរបែបជារនៃសេដ្ឋកិច្ចនៅនឹងកន្លែង</u>

ក. នៅចុងបញ្ចប់នៃសំណួរទី២ (Q2) ចាប់ផ្តើមយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចដឹកនាំដោយសហគមន៍។

ខ. នៅចុងបញ្ចប់នៃសំណួរទី៤ (Q4) ធ្វើការជាមួយនឹងក្រុមការងារអន្តរអង្គភាព (IDT) ដែលផ្តោត លើកិច្ចការទំនាក់ទំនងខាងក្រៅ ដើម្បីរៀបចំឲ្យមានមជ្ឈមណ្ឌលបណ្តុះបណ្តាល និងមជ្ឈមណ្ឌល ផ្តល់ព័ត៌មានការងារនៃអន្តរទីភ្នាក់ងារ ក្នុងការផ្សព្វផ្សាយកម្មវិធីអាជីពការងាររបស់កំពង់ផែ។

គ. នៅចុងបញ្ចប់នៃសំណួរទី៤ (Q4) សិក្សា និងស្វែងរកលទ្ធភាពដោយផ្តល់សិទ្ធិស្របច្បាប់ដល់កំពង់ផែ ក្នុងការដោះស្រាយបញ្ហានៃការប្រឆាំងនឹងផ្លាស់ប្តូរលំនៅដ្ឋាន។ ចាប់ផ្តើមរៀបចំសិក្ខាសាលាអំពីការប្រឆាំងនឹងការផ្លាស់ប្តូរលំនៅដ្ឋាន ដែលអាចជួយបណ្តុះបណ្តាលក្រុមការងារ IDT និងសហគមន៍ ចំពោះសកម្មភាព និងយុទ្ធសាស្ត្រផ្សេងៗនៃកម្មវិធីនេះ។

## ឯកសារភ្ជាប់ B៖ គំរូនៃផែនការវាយតម្លៃ

### ក. សេចក្ដីផ្ដើម

ផែនការវាយតម្លៃ គឺជាផែនទីបង្ហាញផ្លូវមួយដែលកំណត់វិធានការចាំបាច់ ក្នុងការវាយតម្លៃអំពីដំណើរការ និងលទ្ធផលរបស់កម្មវិធីសមភាពរបស់សហគមន៍ជ្រលងភ្នំ*ឌូវ៉ាមីស្ស* (DVCEP)។ ផែនការវាយតម្លៃនេះ មានដូចជា៖ ១. ពិពណ៌នាអំពីកម្មវិធី DVCEP និងរបៀបដែលសកម្មភាពរបស់កម្មវិធីនេះរួមចំណែកដល់ផលប៉ះពាល់ដែលរំពឹងទុក ២. បញ្ជាក់ពីគោលបំណង និងលទ្ធផលរំពឹងទុករបស់កម្មវិធី DVCEP ៣. បង្ហាញពីដំណើរការអនុវត្តន៍កម្មវិធី DVCEP និង ផ្ដល់ព័ត៌មានអំពីកម្មវិធី DVCEP ថាតើកម្មវិធីនេះកំពុងដំណើរការដូចបានគ្រោងទុក និងសម្រេចគោលដៅ ព្រមទាំងបង្ហាញពីការផ្លាស់ប្ដូររបស់កម្មវិធី DVCEP ត្រូវធ្វើ។

### ខ. មាតិកានៃផែនការវាយតម្លៃ

ឯកសារនេះ មានបង្ហាញដូចខាងក្រោម៖

១. ការពិពណ៌នាអំពីកម្មវិធី DVCEP។

២. គម្រូជាក់លាក់ និងក្រាហ្វិកបង្ហាញពី ទំនាក់ទំនងរវាងសកម្មភាព និងផលប៉ះពាល់ដែលរំពឹងទុករបស់កម្មវិធី DVCEP។

៣. ការផ្ដោតលើការវាយតម្លៃ ឬសំណួរចាំបាច់អំពីការវាយតម្លៃ ដែលទាញយកលក្ខណៈវិនិច្ឆ័យ ក្នុងការផ្ដល់អាទិភាពដល់វិធានការណ៍គ្រប់គ្រង និងប្រព័ន្ធវាស់វែង។

៤. វិធីសាស្ត្រក្នុងការអនុវត្តន៍ការវាយតម្លៃ មានដូចជាសូចនាករវាយតម្លៃ ការវាស់វែងដែលបានមកពីការពិសោធន៍ ប្រភពទិន្នន័យ វិធីសាស្ត្រប្រមូលទិន្នន័យ តួនាទី និងភារកិច្ច។

៥. ការពន្យល់ពីរបៀបនៃការវិភាគ និងបកស្រាយព័ត៌មាន លទ្ធផលអ្នកចូលទស្សនា និងពេលវេលាដែល នឹងត្រូវផ្សព្វផ្សាយ។

៦. វិធីសាស្ត្រក្នុងការផ្សព្វផ្សាយលទ្ធផលដល់ភាគីពាក់ព័ន្ធ។

គម្រូនៃប្រព័ន្ធវាស់វែងរបស់ផែនការវាយតម្លៃ / តើការអនុវត្តន៍វិធានការណ៍នេះមានផលប៉ះពាល់អ្វីខ្លះដល់សហគមន៍?

| គោលដៅ CBC របស់សហគមន៍ជ្រលងភ្នំ *ខ្វាំមីស្ស* | វិធានការណ៍គន្លឹះ | សូចនាករ / ការវាស់វែងដោយការពិសោធន៍ | វិធីសាស្ត្រ | ប្រភពទិន្នន័យ | អត្រាដែលកើតឡើង | អ្នកដឹកនាំ | គម្រោងផែនការ១០០ឆ្នាំ - គោលដៅ | គម្រោងផែនការ១០០ឆ្នាំ - ប្រព័ន្ធវាស់វែងគន្លឹះ |
|---|---|---|---|---|---|---|---|---|
| គោលដៅទី១៖ ការកសាងសមត្ថភាពសម្រាប់កិច្ចសហប្រតិបត្តិបន្តរវាងសហគមន៍ និងកំពង់ផែ | ព្រឹត្តិការណ៍ផ្សព្វផ្សាយរបស់កំពង់ផែដែលផ្តោតលើប្រជាជនមិនស្ទាត់ជំនាញក្នុងការប្រើប្រាស់ភាសាអង់គ្លេស | -សមាជិកសហគមន៍ដែលមានការយល់ដឹងខ្ពស់ក្នុងការសហការជាមួយនឹងកំពង់ផែ | ការសង្កេត | ទិន្នន័យទទួលបានតាមការចុះសង្កេតផ្ទាល់ដល់ទីកន្លែង | ទិន្នន័យដែលប្រមូលបាននៅមុន និងក្រោយ សំណួរទី៤ (Q4) | អង្គភាពទំនាក់ទំនងខាងក្រៅនៃកំពង់ផែ *ស៊ីអាថល* | គោលដៅទី១២៖ បង្កើនការបណ្តុះបណ្តាលអំពីកម្លាំងពលកម្ម ឱកាសការងារ និងអាជីវកម្មសម្រាប់សហគមន៍ចំពោះការធ្វើពាណិជ្ជកម្ម ដំណើរកំសាន្ត និងការដឹកជញ្ជូន | -ការងារ/ការស្វែងរកកន្លែងហ្វឹកហាត់ការងារ។<br>-ការរក្សាទុកបុគ្គលិក/ការតម្លើងតំណែងបុគ្គលិក។<br>-ការប្រើប្រាស់ និងការជ្រើសរើសបុគ្គលិកអាទិភាព ។<br>-ការងារផ្សារភ្ជាប់នឹងការរៀនសូត្រ (និយោជក និងនិស្សិត) |
| គោលដៅទី២៖ បរិស្ថានស្អាត និងសហគមន៍ស្អាត | កម្មវិធីអប់រំអំពីគុណភាពខ្យល់ | -សមាជិកសហគមន៍ដែលចូលរួមកម្មវិធីអប់រំ។<br>-បង្កើនការយល់ដឹងអំពីការបំភាយផ្សែងពុលនៅតាមកំពង់ផែ។ | ការសង្កេត និងការប្រមូលទិន្នន័យបែបគុណវិស័យ | ចុះសម្ភាសន៍ផ្ទាល់ដល់ទីកន្លែងនិងទិន្នន័យទទួលបានតាមការសង្កេត | ទិន្នន័យដែលប្រមូលបាននៅចុងបញ្ចប់នៃសំណួរទី៣(Q3) | អាជ្ញាធរកំពង់ផែសមុទ្រនៅភាគពាយ័ព្យ | គោលដៅទី១៥៖ កាត់បន្ថយការបំពុលបរិយាកាស និងបំភាយឧស្ម័ន Carbon | -ការបំភាយភាគល្អិតក្នុងខ្យល់ (PM) កម្រិត ២,៥ (metric tons)/(ភាគរយដែលបានកាត់បន្ថយ)។<br>-ការបំភាយភាគល្អិតក្នុង ប្រេងម៉ាស៊ូត (metric tons)/ (ភាគរយដែលបានកាត់បន្ថយ)។<br>-ការបំភាយឧស្ម័នផ្ទះកញ្ចក់នៅតាមកំពង់ផែ (metric tons )(ភាគរយដែលបានកាត់បន្ថយ)។ |
| គោលដៅទី៣៖ ភាពរុងរឿងនៃសេដ្ឋកិច្ចនៅក្នុងតំបន់ | បណ្តុះបណ្តាលការបណ្តាក់ទុនអាជីកម្មផ្សេងទៀតតាមរយៈការផ្សព្វផ្សាយ | -អ្នកចូលរួមដែលទទួលបានការវិធីបណ្តុះបណ្តាល។<br>-បង្កើនការយល់ដឹងអំពីការទទួលបានកិច្ចសន្យាពីកំពង់ផែ។ | ការសង្កេត និងការប្រមូលទិន្នន័យបែបគុណវិស័យ | បទសម្ភាសន៍ជាមួយនឹងម្ចាស់អាជីវកម្ម | ទិន្នន័យដែលប្រមូលបាននៅចុងបញ្ចប់នៃសំណួរទី៤ (Q4) | អង្គភាពអភិវឌ្ឍន៍សេដ្ឋកិច្ចនៃកំពង់ផែ *ស៊ីអាថល* | គោលដៅទី១០៖ បង្កើនសហគ្រាសដែលមានស្ត្រីឬជនជាតិភាគតិចជាម្ចាស់អាជីវកម្ម (WMBE) ចំនួនបីដង ដែលចុះកិច្ចសន្យាជាមួយនឹងកំពង់ផែ និងបង្កើនចំនួន១៥%-% of dollars ចំណាយលើកិច្ចសន្យារយៈពេល៥ឆ្នាំ ២០១៨-២០២៣។ | -ចំនួនសរុប និងចំនួនបែងចែកនៃ WMBE។<br>-ភាគរយនៃកំពង់ផែដែលចំណាយលើជំនួយរបស់ WMBE ទាំងសរុប និងបែងចែក។ |